# សារៈសំខាន់នៃឈ្មោះមួយ

*ដោយអែលឌើរ អិម រ័សុល បាឡឺដ*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

តាំងពីសន្និសីទទូទៅកាលពីខែមេសាមុន ចិត្តខ្ញុំបានផ្ដោតដដែលៗ លើប្រធានបទអំពីសារៈសំខាន់នៃឈ្មោះមួយ ។ ក្នុងពីរបីខែចុងក្រោយនេះ មានចៅទួតជាច្រើន បានកើតមកក្នុងគ្រួសារយើង ។ ទោះជាពួកគេហាក់ដូចជាកើតមកលឿនជាងអ្វី ដែលខ្ញុំចាប់អារម្មណ៍ ក៏ចៅម្នាក់ៗជាការបន្ថែមដ៏រីករាយដល់គ្រួសារយើង ។ ចៅម្នាក់ៗ បានទទួលឈ្មោះពិសេសមួយ ដែលបានរើសដោយឪពុកម្ដាយគេ ជាឈ្មោះមួយដែលត្រូវបានគេស្គាល់អស់មួយឆាកជីវិតគេ ដែលញែកគេចេញពីអ្នកផ្សេងៗទៀត ។ នេះគឺពិតក្នុងគ្រប់ក្រុមគ្រួសារ ហើយវាក៏ត្រូវក្នុងចំណោមសាសនានានាក្នុងពិភពលោកផងដែរ ។

ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានជ្រាបថា វាសំខាន់យ៉ាងណាក្នុងការដាក់ឈ្មោះសាសនាចក្រទ្រង់ ឲ្យបានច្បាស់លាស់ក្នុងថ្ងៃចុងក្រោយនេះ ។ ក្នុងកណ្ឌទី 115 នៃ គោលលទ្ធិ និងសេចក្ដីសញ្ញា ទ្រង់ផ្ទាល់បានដាក់ឈ្មោះសាសនាចក្រ ៖ « ត្បិតសាសនាចក្ររបស់យើង នឹងត្រូវបានហៅថាដូច្នោះ ហើយនៅគ្រាចុងក្រោយបង្អស់ គឺជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ( ខ 4 ) ។

ហើយស្ដេច បេនយ៉ាមីន បានបង្រៀនប្រជាជនទ្រង់ ក្នុងសម័យព្រះគម្ពីរមរមនថា ៖ « យើងចង់ឲ្យអ្នករាល់គ្នាទទួលដាក់លើខ្លួន នូវព្រះនាមនៃព្រះគ្រីស្ទ គឺអស់អ្នករាល់គ្នា ដែលបានចូលក្នុងសេចក្ដីសញ្ញាជាមួយនឹងព្រះថា អ្នករាល់គ្នានឹងគោរពតាមទ្រង់ រហូតដល់អស់មួយជីវិតរបស់អ្នក... ។ ហើយយើងចង់ឲ្យអ្នករាល់គ្នាចងចាំដែរថា ឈ្មោះនេះហើយដែលយើងបាននិយាយថា យើងនឹងឲ្យទៅអ្នក ដែលនឹងពុំត្រូវលុបចេញឡើយ លើកលែងតែតាមរយៈការរំលងច្បាប់ប៉ុណ្ណោះ ហេតុដូច្នេះហើយ ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន កុំរំលងច្បាប់ ដើម្បីកុំឲ្យឈ្មោះនោះត្រូវលុបចេញពីដួងចិត្តរបស់អ្នកឡើយ » ( ម៉ូសាយ 5:8, 11 ) ។

យើងយកព្រះនាមនៃព្រះគ្រីស្ទដាក់លើខ្លួនយើង ក្នុងទឹកនៃបុណ្យជ្រមុជទឹក ។ យើងរំឭកពីផលនៃបុណ្យជ្រមុជទឹកនោះ រៀងរាល់សប្ដាហ៍ ពេលយើងទទួលទានសាក្រាម៉ង់ ដោយធ្វើសញ្ញាថា ព្រមលើកដាក់មកលើខ្លួនយើងនូវព្រះនាមទ្រង់ និងសន្យាថា ចងចាំទ្រង់ជានិច្ច ( សូមមើល គ. និង ស. 20:77, 79 ) ។

តើយើងដឹងទេថា យើងមានពរជ័យយ៉ាងណា ដែលបានលើកព្រះនាមព្រះរាជបុត្រា សំណព្វតែមួយរបស់ព្រះ ដាក់លើខ្លួនយើងនោះ ? តើយើងយល់ថា ការណ៍នោះ សំខាន់យ៉ាងណាទេ ? ព្រះនាម នៃព្រះអង្គ សង្គ្រោះជានាមតែមួយគត់នៅក្រោមស្ថានសួគ៌ ដែលមនុស្ស អាចបានសង្គ្រោះ ( សូមមើល នីហ្វៃទី2 31:21 ) ។

ដូចដែលអ្នកចាំពីប្រធាន ប៊យដ៍ ឃេ ផាកកឺ បានមានប្រសាសន៍ពីសារៈសំខាន់នៃឈ្មោះរបស់សាសនាចក្រ ក្នុងសន្និសីទទូទៅកាលពីខែមេសានេះ ។ លោកបានពន្យល់ថា « ព្រោះយើងគោរពដល់វិវរណៈ យើងហៅខ្លួនយើងថា សាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជាជាងសាសនាចក្រមរមន » ( «Guided by the Holy Spirit» *Liahona* and *Ensign,* May 2011 ទំព័រ 30 ) ។

ព្រោះឈ្មោះពេញ នៃសាសនាចក្រសំខាន់ខ្លាំង នោះខ្ញុំយល់ស្រប នឹង វិវរណៈទាំងឡាយចេញពីព្រះគម្ពីរ សេចក្ដីណែនាំក្នុងលិខិតរបស់គណៈប្រធានទីមួយឆ្នាំ 1982 និង ឆ្នាំ 2001 និងពាក្យរបស់សាវកផ្សេងៗទៀត ដែលបានលើកទឹកចិត្តសមាជិកនៃសាសនាចក្រ ឲ្យការពារ និងបង្រៀនពិភពលោកថា សាសនាចក្រ ត្រូវបានស្គាល់តាមព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ នេះជាឈ្មោះដែលព្រះអម្ចាស់ នឹងហៅយើងនៅថ្ងៃចុងក្រោយ ។ នេះជាឈ្មោះដែលសាសនាចក្រទ្រង់ នឹងត្រូវបានញែកចេញពីសាសនាចក្រផ្សេងៗទៀត ។

ខ្ញុំបានគិតច្រើនពីហេតុដែលព្រះអង្គសង្គ្រោះ បានប្រទានឈ្មោះដ៏វែងដល់សាសនាចក្រដែលបានស្ដារឡើងវិញរបស់ទ្រង់ ។ វាហាក់ដូចជាវែង តែបើយើងគិតពីវាថា ជាការអធិប្បាយមួយពីសាសនាចក្រនេះវិញ រំពេចនោះ វាក្លាយជាការសង្ខេបមួយដ៏អស្ចារ្យ បរិសុទ្ធ និងត្រង់ៗ ។ តើមានការអធិប្បាយណាមួយ ដែលចំៗ និងច្បាស់លាស់ តែប្រើពាក្យបន្តិចបន្តួចបែបនេះនោះ ? គ្រប់ពាក្យបញ្ជាក់យ៉ាងច្បាស់ និងចាំបាច់ ។ វាចង្អុលបង្ហាញពីទីជំហរនៃសាសនាចក្រដែលបានស្ដារឡើងវិញ ក្នុងចំណោមសាសនាឯទៀតក្នុងពិភពលោកនេះ ។

ពាក្យ *សាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ* ប្រកាសថា វាជាសាសនាចក្ររបស់ទ្រង់ ។ ក្នុងព្រះគម្ពីរមរមន ព្រះយេស៊ូវ បានបង្រៀនថា « ហើយតើនេះជាសាសនាចក្ររបស់យើងដូចម្ដេចកើត លើកលែងតែហៅតាមនាមយើង ? ត្បិតបើសិនជាសាសនាចក្រនេះ ហៅតាមឈ្មោះលោកម៉ូសេ នោះជាសាសនាចក្ររបស់លោកម៉ូសេហើយ ឬបើសិនជាសាសនាចក្រនេះហៅតាមឈ្មោះរបស់បុរសណាម្នាក់ នោះជាសាសនាចក្ររបស់បុរសនោះហើយ តែបើសិនជាសាសនាចក្រនេះ ហៅតាមនាមយើង នោះទើបជាសាសនាចក្ររបស់យើង ប្រសិនបើគេបានសង់លើដំណឹងល្អរបស់យើង » ( នីហ្វៃទី3 27:8 ) ។

*ថ្ងៃចុងក្រោយ* ពន្យល់ថា វាជាសាសនាចក្រដដែល ដូចសាសនាចក្រដែលព្រះយេស៊ូវគ្រីស្ទ បានស្ថាបនា អំឡុងការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ តែត្រូវបានស្ដារឡើងវិញ ក្នុងថ្ងៃចុងក្រោយនេះ ។ យើងដឹងថា មានការធ្លាក់ ឬការក្បត់សាសនាដែលចាំបាច់ត្រូវមានការស្ដារឡើងវិញនៃសាសនាចក្រដ៏ពិត និងពេញលេញរបស់ទ្រង់ នៅក្នុងជំនាន់យើង ។

*ពួកបរិសុទ្ធ* មានន័យថា សមាជិករបស់សាសនាចក្រ ដែលដើរតាមទ្រង់ និងពុះពារធ្វើតាមព្រះទ័យទ្រង់ រក្សាបទបញ្ញត្តិទ្រង់ និងរៀបចំដើម្បីរស់នៅក្នុងវត្តមានទ្រង់ និងព្រះវរបិតាសួគ៌របស់យើងម្ដងទៀត ។ ជាសាមញ្ញ *ពួកបរិសុទ្ធ* សំដៅលើពួកអ្នកដែលព្យាយាមធ្វើឲ្យជីវិតគេបានបរិសុទ្ធ ដោយការធ្វើសេចក្ដីសញ្ញា ដើម្បីដើរតាមព្រះគ្រីស្ទ ។

ឈ្មោះដែលព្រះអង្គសង្គ្រោះ បានប្រទានដល់សាសនាចក្រទ្រង់ ប្រាប់យើងយ៉ាងច្បាស់ថា យើងជានរណា និងអ្វីដែលយើងជឿ ។ យើងជឿថា ព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះនៃមនុស្សគ្រប់គ្នា ។ ទ្រង់បានធ្វើដង្វាយធួនសម្រាប់អស់អ្នកដែលនឹងប្រែចិត្តពីបាបរបស់គេ ហើយទ្រង់បានផ្ដាច់ចំណងទាំងឡាយ នៃសេចក្ដីស្លាប់ និងប្រទាននូវការរស់ពីស្លាប់ឡើងវិញ ។ យើងដើរតាមព្រះយេស៊ូវគ្រីស្ទ ។ ដូចជាស្ដេចបេនយ៉ាមីន បានមានបន្ទូលទៅប្រជាជនទ្រង់ នោះខ្ញុំអះអាងដល់អ្នកទាំងអស់គ្នានៅថ្ងៃនេះថា « អ្នករាល់គ្នាចងចាំថា គួរតែរក្សាព្រះនាម [ ទ្រង់ ] ដោយចារិកនៅក្នុងដួងចិត្តរបស់អ្នកជានិច្ច » ( ម៉ូសាយ 5:12 ) ។

យើងត្រូវបានស្នើឲ្យឈរជាសាក្សីដល់ទ្រង់ « នៅគ្រប់ពេល និងគ្រប់សេចក្ដី និងគ្រប់ទីកន្លែង » ( ម៉ូសាយ 18:9 ) ។ នេះមានន័យថា យើងត្រូវឲ្យអ្នកដទៃដឹងថា យើងដើរតាមអង្គណា ហើយយើងជាកម្មសិទ្ធនៃសាសនាចក្រណា ៖ គឺសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ យើងប្រាកដជាចង់ធ្វើការណ៍នេះក្នុងវិញ្ញាណនៃក្ដីស្រឡាញ់ និងទីបន្ទាល់មួយ ។ យើងចង់ដើរតាមព្រះអង្គសង្គ្រោះ ដោយសាមញ្ញ និងជាក់លាក់ តែដោយរាបទាប ប្រកាសថា យើងជាសមាជិកសាសនាចក្ររបស់ទ្រង់ ។ យើងដើរតាមទ្រង់ ដោយការក្លាយជាពួកបរិសុទ្ធថ្ងៃចុងក្រោយ---ពួកសិស្សថ្ងៃចុងក្រោយ ។

ជាញឹកញាប់ មនុស្ស និងអង្គការនានាត្រូវបានផ្ដល់ឈ្មោះហៅក្រៅដោយអ្នកផ្សេងទៀត ។ ឈ្មោះហៅក្រៅមួយអាចជាទម្រង់ខ្លីនៃឈ្មោះមួយ ឬវាអាចត្រូវបានបង្វែរចេញពីហេតុការណ៍មួយ ឬ លក្ខណៈដើម និងផ្សេងៗទៀត ។ ខណៈដែលឈ្មោះហៅក្រៅពុំមានលក្ខណៈ ឬភាពសំខាន់ដូចជាឈ្មោះពិត នោះឈ្មោះហៅក្រៅនោះ អាចត្រូវបានប្រើតាមសមរម្យ ។

សាសនាចក្ររបស់ព្រះអម្ចាស់ ទាំងពេលបុរាណ និងសម័យទំនើបនេះ មានឈ្មោះហៅក្រៅ ។ ពួកបរិសុទ្ធក្នុងសម័យព្រះគម្ពីរសញ្ញាថ្មី ត្រូវបានហៅថា *ពួកគ្រីស្ទាន* ដោយព្រោះពួកគេមានជំនឿលើព្រះយេស៊ូវគ្រីស្ទ ។ ឈ្មោះនោះត្រូវបានប្រើជាដំបូងដោយពួកអ្នករិះគន់ តែឥឡូវនេះជាឈ្មោះមួយដ៏គួរឲ្យគោរពរាប់អាន ហើយយើងមានកិត្តិយសដោយត្រូវបានហៅថាជា សាសនាចក្រនៃពួកគ្រីស្ទាន ។

សមាជិកយើងត្រូវបានហៅថាជា *ពួកមរមន* ព្រោះយើងជឿលើព្រះគម្ពីរមរមន ៖ សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។ អ្នកផ្សេងទៀតអាចព្យាយាមប្រើពាក្យ *មរមន* ដោយទូលំទូលាយ ដើម្បីបញ្ចូល ឬសំដៅទៅពួកអ្នកដែលបានចេញពីសាសនាចក្រ ហើយបានបង្កើតជាក្រុមតូចៗផ្សេងៗគ្នា ។ ការប្រើប្រាស់បែបនេះនាំឲ្យមានការភាន់ច្រឡំ ។ យើងមានអំណរគុណសម្រាប់ការប្រឹងប្រែងរបស់អ្នកសារព័ត៌មាន ដែលទប់មិនប្រើពាក្យ *មរ-មន* ក្នុងរបៀបមួយដែលធ្វើឲ្យសាធារណៈយល់ច្រឡំសាសនាចក្រជាមួយនឹងអ្នកប្រព្រឹត្តពហុអាពាហ៍ពិពាហ៍ ឬក្រុមមូលដ្ឋានផ្សេងៗទៀត ។ សូមឲ្យខ្ញុំថ្លែងឲ្យបានច្បាស់ថា គ្មានក្រុមអ្នកប្រព្រឹត្តពហុអាពាហ៍ពិពាហ៍ទេ រួមទាំងពួកអ្នកដែលហៅខ្លួនឯងថា ពួកមរមនមូលដ្ឋាន ឬឈ្មោះដែលក្លាយពីឈ្មោះយើង ថាមានជាប់ទាក់ទងអ្វីជាមួយសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយនោះ ។

កាលដែល *មរមន* ពុំមែនជាឈ្មោះពេញ និងត្រឹមត្រូវរបស់សាសនាចក្រ ហើយសូម្បីតែវាត្រូវបានផ្ដល់ពីដំបូង ដោយអ្នករិះគន់យើង អំឡុងពេលដំបូងៗនៃការបៀតបៀនក៏ដោយ ក៏វាបានក្លាយជាឈ្មោះហៅក្រៅមួយដែលអាចទទួលយកបាន ពេលសំដៅចំពោះសមាជិក ជាជាងស្ថាប័នមួយ ។ នៅ

ពេលដែលសមរម្យ យើងមិនចាំបាច់ឈប់ប្រើឈ្មោះ *មរមន* នោះទេ តែយើងគួរបន្តសង្កត់ធ្ងន់ចំពោះឈ្មោះពេញ និងត្រឹមត្រូវរបស់សាសនាចក្រផ្ទាល់ ។ និយាយម្យ៉ាងទៀត គឺយើងគួរចៀសវាង និងមិន ជម្រុញឲ្យប្រើពាក្យ « សាសនាចក្រមរមន » ឡើយ ។

អស់ជាច្រើនឆ្នាំ កាលដែលខ្ញុំបំពេញភារកិច្ចជុំវិញពិភពលោកនោះ ខ្ញុំបានត្រូវសួរជាច្រើនដងថា តើខ្ញុំជារបស់ផងនៃសាសនាចក្រមរមនមែនទេ ។ ចម្លើយរបស់ខ្ញុំ គឺថា « ខ្ញុំជាសមាជិក នៃសាសនាចក្រ ព្រះយេស៊ូវគ្រីស្ទ ។ ពីព្រោះយើងជឿលើព្រះគម្ពីរមរមន ដែលបានដាក់ឈ្មោះតាមព្យាការី និងជាអ្នកដឹកនាំអាមេរិកាំងពីបុរាណ ហើយជាសក្ខីបទមួយទៀត អំពីព្រះយេស៊ូវគ្រីស្ទ នោះជូនកាល យើងត្រូវបានគេហៅថា *ពួកមរមន* » ។ ទោះក្នុងករណីណាក៏ដោយ ចម្លើយនេះត្រូវបានគេទទួលយកយ៉ាងសមរម្យ ហើយតាមពិតទៅ វាបានបើកឱកាសជាច្រើនសម្រាប់ខ្ញុំ ដើម្បីពន្យល់ពីការស្តារឡើងវិញនៃភាពពេញលេញនៃដំណឹងល្អក្នុងថ្ងៃចុងក្រោយនេះ ។

បងប្អូនប្រុសស្រី គ្រាន់តែគិតពីឥទ្ធិពលមួយ ដែលយើងអាចមាន ដោយការឆ្លើយតបដ៏សាមញ្ញ តាមការប្រើឈ្មោះពេញនៃសាសនាចក្រ ដូចដែលព្រះអម្ចាស់បានប្រកាសថា យើងគប្បីធ្វើនោះ ។ ហើយបើអ្នកមិនអាចប្រើឈ្មោះពេញភ្លាមៗទេ យ៉ាងហោចណាស់និយាយថា « ខ្ញុំជារបស់ផងនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ » ហើយក្រោយមកពន្យល់ពីឃ្លា « នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » ។

អ្នកខ្លះអាចសួរថា ចុះគេហទំព័រតាមអិនធើរណិត ដូចជា Mormon.org ក៏ដូចជាយុទ្ធនាការតាមបណ្តាញផ្សព្វផ្សាយផ្សេងៗ ដែលផ្តួចផ្តើមដោយសាសនាចក្រនោះ ។ ដូចខ្ញុំបាននិយាយហើយ ការសំដៅជារួមដល់សមាជិក ជូនកាលជាការសមរម្យ ។ វាជាការងាយប្រើមួយ សម្រាប់អ្នកដែលមិននៅក្នុងសាសនាយើង រកមើលពួកយើងតាមអិនធើរណិត ដោយស្វែងរកពាក្យនោះ ។ តែពេលអ្នកបើកគេហទំព័រ Mormon.org នោះឈ្មោះត្រឹមត្រូវរបស់សាសនាចក្រ ត្រូវបានបង្ហាញនៅទំព័រមុខគេ ហើយវាមាននៅលើគ្រប់ទំព័រផ្សេងទៀតនៃគេហទំព័រនេះ ។ វាមិនងាយទេ ដែលចង់ឲ្យមនុស្សវាយឈ្មោះពេញរបស់សាសនាចក្រ នៅពេលស្វែងរកយើង ឬពេលចូលទៅកាន់គេហទំព័ររបស់យើងនោះ ។

ពេលតម្រូវការងាយៗទាំងនេះ អាចបន្តមានតទៅទៀត នោះតម្រូវការទាំងនោះ មិនគួររារាំងពួកសមាជិកពីការប្រើឈ្មោះពេញរបស់សាសនាចក្រ នៅគ្រប់ពេលដែលអាចធ្វើបាននោះឡើយ ។ ចូរយើងអភិវឌ្ឍទម្លាប់នោះក្នុងគ្រួសារ ក្នុងសកម្មភាពសាសនាចក្រ និងទំនាក់ទំនងប្រចាំថ្ងៃរបស់យើង ក្នុងការធ្វើឲ្យវាច្បាស់លាស់ថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជាឈ្មោះដែលព្រះអម្ចាស់ផ្ទាល់ បានបញ្ជាថា យើងត្រូវឲ្យគេស្គាល់ដោយឈ្មោះនោះ ។

ការស្ទង់មតិថ្មីៗមួយបានបញ្ជាក់ថា មានមនុស្សជាច្រើនណាស់នៅតែមិនយល់ដោយត្រឹមត្រូវថា *មរមន* សំដៅលើសមាជិកនៃសាសនាចក្រយើង ។ ហើយមនុស្សមួយចំនួនធំនៅតែមិនប្រាកដថា ពួកមរមន ជាពួកគ្រីស្ទាន ។ សូម្បីពេលពួកគេអានពីដៃជំនួយរបស់យើង ដែលធ្វើឡើងនៅទូទាំងពិភពលោក បន្ទាប់ពីរងនូវ ព្យុះសង្ឃរា ការរញ្ជួយដី ទឹកជំនន់ និងគ្រោះអត់ឃ្លានក៏ដោយ ក៏ពួកគេពុំបានបញ្ចូលកិច្ចការមនុស្សធម៌របស់យើង និងយើងថាជាអង្គការពួកគ្រីស្ទាននោះដែរ ។ ប្រាកដណាស់ បើសិនជាយើងហៅខ្លួនយើងថា ជាសមាជិក នៃសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នោះវានឹងងាយសម្រាប់ពួកគេ ដើម្បីយល់ថា យើងជឿ និងដើរតាមព្រះអង្គសង្គ្រោះ ។ តាមរបៀបនេះ ពួកអ្នកដែលឮឈ្មោះ *មរមន* នឹងភ្ជាប់ទំនាក់ទំនងពាក្យនោះ នឹងឈ្មោះដែលបានបើកសម្តែងជាមួយនឹងមនុស្ស ដែលដើរតាមព្រះយេស៊ូវគ្រីស្ទ ។

ពេលគណៈប្រធានទីមួយ បានស្នើក្នុងលិខិតរបស់ពួកលោក ក្នុងថ្ងៃទី 23 ខែ កុម្ភៈ ឆ្នាំ 2001 ថា ៖ « ក្នុងការប្រើឈ្មោះដែលបានបើកសម្តែង គឺសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺរឹតតែសំខាន់ ក្នុងការទទួលខុសត្រូវរបស់យើង ដើម្បីប្រកាសពីព្រះនាមនៃព្រះអង្គសង្គ្រោះ នៅទូទាំងពិភពលោក ។ ដោយហេតុផលនោះ យើងស្នើថា ពេលយើងសំដៅទៅលើសាសនាចក្រ យើងប្រើឈ្មោះពេញនៅពេលណាក៏ដោយ ដែលអាចធ្វើបាន » ។

ក្នុងឆ្នាំ 1948 នៅសន្និសីទទូទៅខែ តុលា ប្រធានចច អ័លប៊ើត ស្ម៊ីធ បានមានប្រសាសន៍ថា « បងប្អូនប្រុសស្រី ពេលអ្នកចាកចេញពីសន្និសីទនៅថ្ងៃនេះ អ្នកអាចប្រាស្រ័យទាក់ទងនឹងក្រុមសាសនាផ្សេងៗទៀត ក្នុងពិភពលោកនេះ តែសូមចងចាំថា មានតែសាសនាចក្រមួយប៉ុណ្ណោះក្នុងពិភពលោកនេះ ដែលប្រកាន់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់របស់យើង ដោយការបញ្ជាដ៏ទេវភាព » ( ក្នុង Conference Report Oct. 1948 ទំព័រ 167 ) ។

បងប្អូនប្រុសស្រី សូមឲ្យយើងចងចាំដំបូន្មាននេះផងដែរ ពេលយើងចាកចេញពីសន្និសីទនៅថ្ងៃនេះ ។ ចូរឲ្យទីបន្ទាល់របស់យើងពីទ្រង់ និងសេចក្តីស្រឡាញ់យើងចំពោះទ្រង់ មាននៅក្នុងដួងចិត្តយើងជានិច្ច ។ ខ្ញុំសូមអធិស្ឋាននៅក្នុងព្រះនាម ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។